កិច្ចការ២១:២៧-២២:៣០

## គេចាប់ខ្លួនសាវ័កប៉ុលនៅទីក្រុងយេរូសាឡិម

> [២៧]កាលជិតគ្រប់៧ថ្ងៃនោះហើយ នោះពួកសាសន៍យូដាពីស្រុក
> អាស៊ី គេឃើញប៉ុលក្នុងព្រះវិហារ ក៏ញុះញង់ដល់បណ្តាមនុស្ស
> ទាំងប៉ុន្មាន រួចលូកដៃទៅចាប់យកគាត់ហើយស្រែកថា [២៨]នែ អ្នក
> រាល់គ្នា ជាសាសន៍អ៊ីស្រាអែលអើយ មកជួយគ្នា នេះហើយ
> ជាមនុស្សដែលបង្រៀនដល់មនុស្សទាំងអស់ នៅគ្រប់ទីដំបន់ ឲ្យ
> ទាស់នឹងសាសន៍យើង នឹងក្រិត្យវិន័យ ហើយទីនេះដែរ ឥឡូវនេះ
> បាននាំទាំងសាសន៍ក្រេកចូលមកក្នុងព្រះវិហារ ធ្វើបង្អាប់ទី
> បរិសុទ្ធនេះថែមទៀតផង (កិច្ចការ២១:២៧-២៨)។

ធម្មតាពួកបាតុករតែងតែស្រែកតៗគ្នាមិនដឹងថា រឿងអ្វីមួយពិត ឬមិនពិតទេ។

> ដំណើរនេះគេស្មានថា គាត់នាំសាសន៍ក្រេកនោះទៅក្នុងព្រះ
> វិហារ ដោយព្រោះពីថ្ងៃមុន គេឃើញទ្រភីម ជាអ្នកស្រុកអេភេ
> សូរ នៅជាមួយនឹងគាត់ក្នុងទីក្រុង (កិច្ចការ២១:២៩)។

សាវ័កប៉ុលមានលក្ខណៈដោយឡែក មិនដូចពួកអ្នកនាំគេបះបោរពីមុនៗ មកទេ។ លោកស្គាល់ទំនៀមទម្លាប់ប្រពៃណីរបស់សាសន៍យូដា។ លោកចូលទៅថ្វាយបង្គំព្រះនៅក្នុងព្រះវិហារ។ លោកទ្រភីម គឺជាសាសន៍ដទៃមកពីទីក្រុងអេភេសូរ។ លោកជឿដល់ព្រះអម្ចាស់យេស៊ូវតាមរយៈសាវ័កប៉ុលផ្សាយដំណឹងល្អ។ ពេលលោកមកដល់ព្រះវិហារទីក្រុងយេរូសាឡិមជាមួយសាវ័កប៉ុល លោកមិនធ្វើតាមប្រពៃណីទំនៀមទម្លាប់ដូចសាវ័កប៉ុលទេ។ ក្នុងនាមលោកជាគ្រីស្ទបរិស័ទសាសន៍ដទៃ លោកមានសិទ្ធិនឹងមិនចូលរួមគោរពប្រពៃណីរបស់សាសន៍យូដាឡើយ។ នៅក្រោមព្រះគុណ លោកមានសេរីភាព។ ចំណែកសាវ័កប៉ុលវិញ លោកជ្រាបថា ការលាបំណន់មិនមានអ្វីទាក់ទងជាមួយនឹងសេចក្តីសង្គ្រោះរបស់លោកទេ។ ទោះសាសន៍យូដា ទោះសាសន៍ដទៃ សុទ្ធតែបានទទួលរួចពីបាប ដោយសារព្រះគុណរបស់ព្រះតាមរយៈអង្គព្រះយេស៊ូវគ្រីស្ទដូចៗគ្នា។

ពេលលាបំណន់ សាវ័កប៉ុលប្រហែលជាគ្រាន់តែតម និងទទួលទានអាហារមួយប្រភេទតែប៉ុណ្ណោះ។ លោកកើតមកស្គាល់ប្រពៃណីទំនៀមទម្លាប់យ៉ាងដូច្នោះ។ សព្វថ្ងៃគ្រីស្ទបរិស័ទតាមនិកាយ តាមជំនឿ តែងតែទទួលទានរបស់នេះមួយ មិនទទួលទានរបស់នោះមួយ។ រឿងនោះ ជារឿងធម្មតាទេ។ ប៉ុន្តែ សូមជ្រាបថា ការតមឬបរិភោគម្ហូបអាហារប្រភេទណាមួយ មិនបានធ្វើអោយខ្លួនទាក់ទងជាមួយនឹងព្រះជាម្ចាស់គ្រាន់ប្រសើរឡើងនោះទេ។ យើងជារាស្ត្ររបស់ព្រះជាម្ចាស់ត្រូវរៀនអោយ

ស្គាល់ពីការនេះ អោយបានច្បាស់លាស់។

> **[៣០]នោះក្រុងទាំងមូលក៏កើតជ្រួលជ្រើមបណ្តាជនទាំងឡាយ គេរត់មកមូលគ្នា កាលចាប់ប៉ុលបានហើយ នោះគេទាញកន្ត្រាក់គាត់ចេញទៅខាងក្រៅព្រះវិហារ រួចបិទទ្វារភ្លាម [៣១]តែកំពុងដែលគេរកចន្លោះសំឡាប់គាត់ នោះដំណឹងក៏ឮផ្សាយទៅដល់មេទ័ពធំថា មានកើតវឹកវរពេញក្នុងក្រុងយេរូសាឡិម [៣២]លោកក៏យកទាហាន នឹងមេទ័ពរង នាំរត់ចុះទៅឯគេភ្លាម កាលឃើញលោកនឹងទាហានមកដល់ គេក៏ឈប់លែងវាយប៉ុល (កិច្ចការ២១:៣០-៣២)។**

សាសន៍យូដាមានការគុំគួនជាមួយនឹងសាវ័កប៉ុលយ៉ាងខ្លាំង។ ពួកសាសន៍យូដាស្អប់សាវ័កប៉ុល ពីព្រោះលោកបង្រៀនថា ដើម្បីទទួលសេចក្តីសង្គ្រោះពីព្រះអម្ចាស់យេស៊ូវ មនុស្សមិនចាំបាច់កាន់តាមច្បាប់របស់លោកម៉ូសេទៀតទេ។ សាវ័កប៉ុលមានសិទ្ធិធ្វើតាមប្រពៃណីរបស់សាសន៍លោក បើលោកចង់ធ្វើយ៉ាងនោះ។ លោកចង់រក្សាប្រពៃណី ពីព្រោះលោកចង់អោយសាសន៍លោកបានជឿដល់ព្រះអង្គដែរ។ ការសម្របសម្រួលបែបនេះ មិនបានសម្រេចតាមគំនិតរបស់លោកទេ ប៉ុន្តែការនេះសម្រេចតាមបំណងព្រះហឫទ័យរបស់ព្រះវិញ។

ពួកបះបោរទាំងអម្បាលមាណពិតជាសម្លាប់សាវ័កប៉ុលមែន បើមេទ័ពមិនបាន បញ្ជាអោយទាហានមកការពារលោកទេ។

## គេដាក់ច្រវាក់សាវ័កប៉ុល

**លោកចូលទៅចាប់គាត់ ហើយបង្គាប់ឱ្យដាក់ច្រវាក់២ខ្សែ រួច សុើបសួរពីគាត់ជាអ្នកណា ហើយបានធ្វើអ្វីខ្លះ (កិច្ចការ២១: ៣៣)។**

លោកមេទ័ពមួយរូបនេះ មិនស្គាល់ថា សាវ័កប៉ុលជានរណាទេ។ លោកមិន ទាំងក្រឡេកមើលសាវ័កប៉ុលផង។ គាត់មិនដឹងថា តើសាវ័កប៉ុលប្រហែលជាមនុស្សណា ម្នាក់ ប្រព្រឹត្តអំពើឧក្រិដ្ឋណាមួយ បានជាលោកចាប់សាវ័កប៉ុលដាក់ច្រវាក់ដល់ទៅ ពីរខ្សែ។

**[៣៤]តែក្នុងហ្វូងមនុស្ស ខ្លះស្រែកយ៉ាងនេះ ខ្លះស្រែកយ៉ាងនោះ**
**ដូច្នេះ លោកពុំអាចនឹងដឹងអ្វីជាប្រាកដបាន ដោយព្រោះមាន**
**សូរសៀងអឺងកងជាខ្លាំង បានជាលោកបង្គាប់ឱ្យនាំគាត់ចូលទៅ**
**ក្នុងបន្ទាយ [៣៥]លុះបានដល់ទៅជណ្ដើរបន្ទាយហើយ នោះពួក**

**ទាហានត្រូវលើកសែងគាត់ឡើង ដោយព្រោះហ្វូងមនុស្ស ច្របូកច្របល់ឡើងជាខ្លាំង [៣៦] ដ្បិតមានបណ្តាជនសន្ធឹកណាស់ដែលដើរតាមមក ទាំងស្រែកថា ឱ្យសំឡាប់វាទៅ (កិច្ចការ២១:៣៤-៣៦)។**

លោកមេទ័ពឮពួកបណ្តាជនចោទប្រកាន់លោក ប៉ុន្តែអ្នកខ្លះចោទសាវ័កប៉ុលថាយ៉ាងនេះ អ្នកខ្លះចោទថាយ៉ាងនោះ។ ដោយសារលោកយកជាការមិនបាន បានជាលោកនាំសាវ័កប៉ុលទៅដាក់ក្នុងបន្ទាយ ដើម្បីស្វែងរកអោយដឹងថា តើលោកធ្វើខុសអ្វី។ ពួកបណ្តាជនគេមិនចង់ដោះស្រាយរឿងសាវ័កប៉ុលទេ គឺគេចង់តែម្យ៉ាង គឺសម្លាប់លោកប៉ុលចោល។

**កាលគេរៀបនឹងនាំប៉ុលចូលទៅក្នុងបន្ទាយ នោះគាត់និយាយទៅមេទ័ពធំថា តើលោកបើកឱ្យខ្ញុំជំរាបបន្តិចបានឬទេ លោកសួរថាឯងចេះនិយាយភាសាក្រេកដែរឬ (កិច្ចការ២១:៣៧)។**

លោកមេទ័ពមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ លោកគិតថា សាវ័កប៉ុលគ្រាន់តែជាមេដឹកនាំអ្នកបះបោរកំប៉ិកកំប៉ុកប៉ុណ្ណោះ។ ផ្ទុយទៅវិញលោកឃើញថា សាវ័កប៉ុលចេះនិយាយភាសាក្រេកយ៉ាងស្ទាត់ជំនាញ។ លោកយល់ច្បាស់អំពីភាសាដែលសាវ័កប៉ុល

និយាយ ពីព្រោះលោកក៏ចេះភាសាក្រេកដែរ។

**ដូច្នេះ តើឯងមិនមែនជាសាសន៍អេស៊ីព្ទនោះ ដែលនាំឲ្យបះបោរអំពីមុន ព្រមទាំងនាំពួកមនុស្សកាប់ចាក់គ្នា៤ពាន់នាក់ ឲ្យទៅនៅទីរហោស្ថានទេឬអី (កិច្ចការ២១:៣៨)។**

លោកមេទ័ពស្មានថា សាវ័កប៉ុលជាមេដឹកនាំការបះបោរដែលធ្វើឡើងសម្រាប់ទាស់ជាមួយនឹងការគ្រប់គ្រងនគរពីសំណាក់ចក្រភពរ៉ូម។

**តែប៉ុលឆ្លើយតបថា ខ្ញុំជាសាសន៍យូដា មកពីក្រុងតើសុស ដែលនៅស្រុកគីលីគា ឯស្រុកកំណើតរបស់ខ្ញុំ មិនមែនជាក្រុងឥតមានកេរ្តិ៍ឈ្មោះនោះទេ ដូច្នេះ សូមលោកបើកឲ្យខ្ញុំនិយាយទៅជនទាំងឡាយបន្តិចសិន (កិច្ចការ២១:៣៩)។**

សាវ័កប៉ុលចេះនិយាយភាសាក្រេកយ៉ាងស្ទាត់ជំនាញ តែលោកបានជម្រាបដល់លោកមេទ័ពថា លោកជាសាសន៍យូដា។ នៅពេលដែលលោកមេទ័ពឮថាសាវ័កប៉ុលចង់និយាយទៅកាន់ពួកបណ្ដាជន លោកឆ្លើយតបថា "បើឯងចង់និយាយ សូមនិយាយចុះ ដ្បិតខ្ញុំមិនដឹងថាឯងជានរណាទេ"។

**លោកក៏បើកឱកាសឱ្យ រួចប៉ុលឈរលើជណ្ដើរ ធ្វើគ្រៀងសំគាល់ នឹងដៃដល់បណ្ដាជន លុះបានស្ងប់ស្ងាត់ហើយ នោះគាត់និយាយទៅគេជាភាសាហេព្រើរថា (កិច្ចការ២១:៤០)។**

សាវ័កប៉ុលនិយាយទៅកាន់លោកមេទ័ពជាភាសាក្រេក តែលោកនិយាយទៅកាន់ពួកបណ្ដាជនដែលសុទ្ធតែជាសាសន៍យូដា ជាភាសាហេព្រើរ។ នៅក្នុងវិនាទីដែលសាវ័កប៉ុលចាប់ផ្ដើមនិយាយជាភាសាហេព្រើរ ពួកបណ្ដាជនស្ដាប់សាវ័កប៉ុលដោយយកចិត្តទុកដាក់ជាទីបំផុត។

# ជំពូក ២២

*ទាចចនា សាវ័កប៉ុលបំភ្លឺរឿងពិតនៅមុខពួកបណ្តាជន*
*សាវ័កប៉ុលប្រាប់គេថា លោកមានសញ្ជាតិជាសាសន៍រ៉ូម*

នៅក្នុងជំពូក២២ សាវ័កប៉ុលមានប្រសាសន៍ទៅកាន់ពួកបណ្តាជន។ លោកជម្រាបពួកបណ្តាជនអំពីដំណើរដែលលោកបានជួបជាមួយនឹងអង្គព្រះគ្រីស្ទ។ មិនតែប៉ុណ្ណោះ លោកជម្រាបអំពីមូលហេតុដែលលោកចាំបាច់ត្រូវចុះមកទីក្រុងយេរូសាឡិមនៅក្នុងពេលនេះ។ បន្ទាប់ពីហេតុការណ៍នោះកើតឡើង សាវ័កប៉ុលបានប្រាប់ដល់អាជ្ញធររាជការរ៉ូមថា លោកមានសញ្ជាតិជាសាសន៍រ៉ូម ដើម្បីកុំអោយគេចេះតែវាយដំប្រំធាក់លោកដោយខ្វះការចោទប្រកាន់នៅមុខច្បាស់តុលាការ។

ឥឡូវ សូមយើងស្តាប់ប្រសាសន៍របស់សាវ័កប៉ុល។ លោកមានដំណឹងសម្រាប់យើងទាំងអស់គ្នា ដែលជាអ្នកស្តាប់ សូម្បីក្នុងសម័យនេះក៏ដោយ។

## សាវ័កប៉ុលបំភ្លឺរឿងពិតនៅមុខពួកបណ្តាជន

**ឱអ្នករាល់គ្នា ជាបងប្អូន ហើយជាឪពុកអើយ សូមស្តាប់សេចក្តី**

**ដោះសារបស់ខ្ញុំសិន (កិច្ចការ២២:១)។**

លោកមានប្រសាសន៍ទៅកាន់ពួកបណ្តាជនថា "ឱអ្នករាល់គ្នា ជាបងប្អូន..."។ សាវ័កប៉ុលត្រូវជាបងប្អូនរួមជាតិជាមួយនឹងពួកបណ្តាជន។ ពួកបណ្តាជនដែលជាសាសន៍ហេព្រើរ ចង់សម្លាប់បងប្អូនឯង។ តើសាវ័កប៉ុលមានលក្ខណៈជ្រុលនិយមដោយប្រការណាមួយឬ បានជាគេចង់សម្លាប់លោក? សាវ័កប៉ុលមានអកប្ប-កិរិយាដូចសាសន៍របស់លោកដែរ។ លោកចេះគួរសមចំពោះពួកចាស់ទុំណាស់។ លោកមានប្រសាសន៍ទៅកាន់ពួកបណ្តាជនទាំងហ្វូងថា "ហើយជាឪពុកអើយ... "។

**(កាលគេឮគាត់និយាយជាភាសាហេព្រើរ នោះគេរឹតតែនៅស្ងៀមទៅទៀត) រួចគាត់និយាយថា (កិច្ចការ២២:២)។**

នៅពេលដែលលោកចាប់ផ្តើមនិយាយ ទៅកាន់ពួកបណ្តាជនជាភាសាហេព្រើរ ពួកបណ្តាជននាំគ្នាស្ងាត់ស្ងៀម ហើយស្តាប់លោក។ ការស្រែកអ៊ូអររបស់ពួកបណ្តាជន បានប្រែទៅជាឈប់ហ្នឹងថ្កល់ដូចទឹកនៅក្នុងផ្តិល។ គេនាំគ្នាស្តាប់ដល់សាវ័កប៉ុល ពីព្រោះគេយល់ថា សាវ័កប៉ុលជាសាសន៍ហេព្រើរដែរ។ លុះដល់ពួកបណ្តាជនស្ងាត់ហើយ លោកក៏ចាប់ផ្តើមជម្រាបដល់បណ្តាជនអំពីប្រវត្តិសង្ខេបរបស់លោកផ្ទាល់។

**ខ្ញុំជាសាសន៍យូដា កើតនៅក្រុងតើសុស ក្នុងស្រុកគីលីគា តែបានរៀននៅទីក្រុងនេះ ទៀបជើងលោកកាម៉ាលាល ដែលលោកបង្រៀនខ្ញុំ តាមន័យត្រឹមត្រូវ ក្នុងក្រិត្យវិន័យរបស់ពួកឰយុកោយើង ហើយខ្ញុំមានសេចក្តីឧស្សាហ៍ដល់ព្រះ ដូចជាអ្នករាល់គ្នាសព្វថ្ងៃនេះដែរ (កិច្ចការ២២:៣)។**

ពួកអ្នកដឹកនាំនយោបាយ និងអ្នកដឹកនាំសាសនាសាសន៍យូដា នាំគ្នាធ្វើទុក្ខបុកម្នេញដល់សាវ័កប៉ុល។ សាវ័កប៉ុលជម្រាបដល់ពួកបណ្តាជនថា លោកក៏ជាអ្នកដឹកនាំសាសនាសាសន៍យូដានៅក្នុងគណៈផារីស៊ីដែរ។ សាវ័កប៉ុលមានចិត្តអាណិតអាសូរដល់អ្នកដែលធ្វើកាបៀតបៀនដល់លោក ដ្បិតលោកក៏ធ្លាប់ធ្វើការបៀតបៀនដល់អ្នកជឿព្រះយេស៊ូវពីមុនដែរ។ លោកចង់អោយមេដឹកនាំសាសនាយូដា បែរមកទទួលជឿព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដូចលោក។

សាវ័កប៉ុលមិនមែនជាមនុស្សល្ងិតល្ងង់ទេ។ លោកទទួលសញ្ញាប័ត្រពីមហាវិទ្យាល័យក្រុងតើសុស។ នៅសម័យនោះ ទីក្រុងតើសេ គឺជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាយ៉ាងខ្ពង់ខ្ពស់ផ្នែកភាសាក្រេក។ បើមានជនណាមួយទទួលសញ្ញាប័ត្រពីមហាវិទ្យាល័យក្រុងតើសុស ជននោះគឺជាអ្នកដែលគេរាប់ថា ជាសិស្សឆ្នើមហើយ។

សាវ័កប៉ុល ទទួលចំណេះចេះដឹងពីមហាវិទ្យាល័យក្រេកនៅទីក្រុងតើសុស។ មិនតែប៉ុណ្ណោះ លោកបានសិក្សាសាសនាយូដានៅទីក្រុងយេរូសាឡិម។ ឯគ្រូរបស់

លោក គឺអ្នកប្រាជ្ញគម្ពីរមួយរូបនាមកាម៉ាលាល។ ពួកបណ្ដាជនកំពុងរង់ចាំស្ដាប់សាវ័កប៉ុលដោយយកចិត្តទុកដាក់។

**ពីដើមខ្ញុំជាអ្នកធ្វើទុក្ខបៀតបៀនដល់មនុស្ស ដែលកាន់តាមផ្លូវនេះ ឱ្យដល់ស្លាប់ក៏មាន ព្រមទាំងចាប់ចងគេទាំងប្រុសទាំងស្រី បញ្ជូនទៅដាក់គុកដែរ (កិច្ចការ២២:៤)។**

សាវ័កប៉ុលមានប្រសាសន៍ថា "ផ្លូវនេះ"។ តើផ្លូវនេះមានន័យយ៉ាងដូចម្ដេច? លោកមិនមែននិយាយផ្លូវនេះ សំដៅទៅលើក្រុមជំនុំឬមួយពួកអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវ ឬមួយក៏អ្នកគ្រីស្ទានទេ។ ផ្លូវនេះ គឺជាផ្លូវដែលព្រះអម្ចាស់យេស៊ូវមានបន្ទូលថា "ទ្រង់ជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត"។ "ផ្លូវនេះ" គឺអង្គព្រះយេស៊ូវគ្រីស្ទ។

សាវ័កប៉ុលចង់ប្រាប់ដល់ពួកបណ្ដាជនថា "សូមស្ដាប់ ខ្ញុំក៏ធ្លាប់ធ្វើជាអ្នកបៀតបៀនដល់ផ្លូវនេះដែរ។ ខ្ញុំយល់ហើយថា ហេតុអ្វីបានជាពួកអស់លោកធ្វើមកកាន់ខ្ញុំដូចខ្ញុំធ្វើទៅកាន់ពួកអ្នកកាន់តាម "ផ្លូវនេះ" ពីមុនមក។

**"ដូចជាសំដេចសង្ឃ នឹងពួកចាស់ទុំទាំងអស់ ជាទីបន្ទាល់ពីខ្ញុំស្រាប់ ហើយខ្ញុំបានទទួលយកសំបុត្រពីលោក ទៅឱ្យពួកសាសន៍**

**យើងនៅក្រុងដាម៉ាស រួចខ្ញុំក៏ចេញទៅ ដើម្បីនឹងនាំយកអស់អ្នក**
**ក្នុងពួកនេះទាំងប៉ុន្មាន ដែលនៅស្រុកនោះទាំងជាប់ចំណង មក**
**ឯក្រុងយេរូសាឡិមវិញ ឲ្យគេជាប់ទោស ៦លុះកាលខ្ញុំកំពុងតែដើរ**
**ដំណើរទៅជិតដល់ក្រុងដាម៉ាស ក្នុងពេលប្រហែលជាថ្ងៃត្រង់**
**ហើយ នោះស្រាប់តែមានពន្លឺយ៉ាងខ្លាំងពីលើមេឃ បានភ្លឺមក**
**នៅជុំវិញខ្ញុំ ៧ខ្ញុំក៏ដួលដល់ដី ហើយឮសំឡេងមានបន្ទូលមកខ្ញុំថា**
**សុល នែសុល ហេតុអ្វីបានជាធ្វើទុក្ខដល់ខ្ញុំ (កិច្ចការ២២:៥-៧)។**

សាវ័កប៉ុលរៀបរាប់អំពីលំដាប់បទពិសោធ ដែលលោកបានជួបកន្លងមក។

**ខ្ញុំបានឆ្លើយថា ឱព្រះអម្ចាស់អើយ តើព្រះអង្គណានុ៎ះ រួចទ្រង់ មានបន្ទូលមកខ្ញុំថា ខ្ញុំជាព្រះយេស៊ូវពីភូមិណាសារ៉ែត ដែលអ្នកបៀតបៀន (កិច្ចការ២២:៨)។**

នៅក្នុងពេលនេះ ពួកបណ្ដាជននាំគ្នាស្ដាប់សាវ័កប៉ុលដោយស្ងាត់ជ្រៀប។

**ឯពួកអ្នកដែលនៅជាមួយនឹងខ្ញុំ គេក៏ឃើញពន្លឺនោះដែរ ហើយ មានសេចក្ដីភ័យខ្លាច តែមិនឮសំឡេងព្រះអង្គដែលមានបន្ទូលមក**

**ខ្ញុំនោះទេ (កិច្ចការ២២:៩)។**

នៅក្នុងខនេះ សូមលោកអ្នកសង្កេតមើលបន្តិច ពីព្រោះមានគេចោទប្រកាន់ថា ពាក្យរបស់សាវ័កប៉ុល ហើយនិងពាក្យរបស់បណ្ឌិតលូកាហាក់ដូចជាខុសគ្នា។ នៅពេលដែលសាវ័កប៉ុលប្រែចិត្តមកជឿដល់ព្រះអម្ចាស់យេស៊ូវ បណ្ឌិតលូកាកត់ត្រាថា "ឯពួកអ្នកដែលដើរជាមួយនឹងគាត់ គេក៏ឈរស្រឡាំងកាំងនៅដោយបានឮសំឡេងមែន តែមិនឃើញអ្នកណាសោះ" (កិច្ចការ៩:៧)។ ចំណែកសាវ័កប៉ុលមានប្រសាសន៍នៅក្នុងខ៩នេះថា "ឯពួកអ្នកដែលនៅជាមួយនឹងខ្ញុំ គេក៏ឃើញពន្លឺនោះដែរ ហើយមានសេចក្តីភ័យខ្លាច តែមិនឮសំឡេងព្រះអង្គដែលមានបន្ទូលមកខ្ញុំនោះទេ"។ តើឃ្លានេះ ខុសគ្នាដូចអ្នកដែលគេចោទប្រកាន់មែនឬមួយយ៉ាងណា?

តាមពិតទៅសាច់រឿងទាំងពីរនេះ មិនខុសគ្នាដោយប្រការណាទេ។ ពួកមនុស្សដែលដើរជាមួយនឹងសាវ័កប៉ុល សុទ្ធតែឮសម្លេងដែលព្រះជាម្ចាស់មានបន្ទូលមកកាន់សាវ័កប៉ុល តែគេមិនយល់ខ្លឹមសារថា សម្លេងនោះជាសម្លេងអ្វីឡើយ។

**"[10]ខ្ញុំក៏ទូលសួរថា ព្រះអម្ចាស់អើយ តើត្រូវឱ្យទូលបង្គំធ្វើដូចម្តេច រួចព្រះអម្ចាស់មានបន្ទូលមកខ្ញុំថា ចូរក្រោកឡើងចូលទៅក្នុងក្រុងដាម៉ាស នៅទីនោះនឹងមានគេប្រាប់អ្នក ពីអស់ទាំងការ ដែលបានដំរូវឱ្យអ្នកត្រូវធ្វើ "នោះពួកអ្នកដែលនៅជាមួយនឹងខ្ញុំបានដឹកដៃ**

**នាំខ្ញុំចូលទៅក្នុងក្រុងដាម៉ាស ពីព្រោះខ្ញុំមើលអ្វីមិនឃើញសោះ**
**ដោយព្រោះរស្មីដ៏ឧត្ដមនៃពន្លឺនោះ ១២រួចមានមនុស្សម្នាក់ឈ្មោះ**
**អាន្នានាស គឺជាអ្នកកោតខ្លាចដល់ព្រះតាមក្រិត្យវិន័យ ដែលមាន**
**កេរ្តិ៍ឈ្មោះល្អក្នុងពួកសាសន៍យូដាទាំងអស់ដែលនៅទីនោះ ១៣អ្នក**
**នោះក៏មកឈរជិតខ្ញុំនិយាយថា អ្នកសុលអើយ សូមឱ្យភ្នែកអ្នក**
**បានភ្លឺឡើង នៅវេលានោះឯង ខ្ញុំក៏ងើបភ្នែកឡើងឃើញគាត់**
**១៤រួចគាត់និយាយមកខ្ញុំថា ព្រះនៃពួកឰយុកោយើងបានជំរូវឱ្យអ្នក**
**ស្គាល់ចំណង់នៃព្រះហឫទ័យទ្រង់ ហើយឱ្យឃើញព្រះដ៏សុចរិត**
**ព្រមទាំងឮសំឡេងពីព្រះឱស្ឋទ្រង់ ១៥ដ្បិតអ្នកត្រូវធ្វើជាស្មរបន្ទាល់**
**ពីទ្រង់ ដល់មនុស្សទាំងអស់ ពីគ្រប់ការដែលអ្នកបានឃើញបានឮ**
**(កិច្ចការ២២: ១០-១៥)។**

សាវ័កប៉ុលបានសន្ទនាជាមួយនឹងព្រះអម្ចាស់យេស៊ូវផ្ទាល់។ ខ្ញុំជឿថា នៅពេលដែលលោកទៅសម្ងំរៀនសូត្រនៅទីរហោស្ថាន នៅស្រុកអារ៉ាប់ ព្រះអម្ចាស់យេស៊ូវបានបង្ហាត់បង្រៀនលោកផ្ទាល់។

**១៦ឥឡូវនេះ តើអ្នកបង្អង់ចាំអ្វីទៀត ចូរក្រោកឡើង ទទួលបុណ្យ**
**ជ្រមុជទឹក ហើយលាងបាបអ្នកចេញចុះ ដោយការអំពាវនាវដល់**

**ព្រះនាមព្រះអម្ចាស់ [១៧]កាលខ្ញុំបានត្រឡប់ទៅឯក្រុងយេរូសាឡិម**
**វិញ កំពុងដែលខ្ញុំអធិស្ឋាននៅក្នុងព្រះវិហារ នោះខ្ញុំលង់ស្មារតីទៅ**
**[១៨]ហើយក៏ឃើញទ្រង់មានបន្ទូលមកខ្ញុំថា ចូរប្រញាប់ចេញពីក្រុង**
**យេរូសាឡិមទៅជាឆាប់ ពីព្រោះគេមិនទទួលពាក្យដែលអ្នកធ្វើ**
**បន្ទាល់ពីខ្ញុំទេ [១៩]ខ្ញុំក៏ទូលថា ព្រះអម្ចាស់អើយ អ្នកទាំងនោះដឹងថា**
**ទូលបង្គំបានចាប់ពួកអ្នកដែលជឿដល់ទ្រង់ដាក់គុកហើយ ព្រម**
**ទាំងវាយគេនៅក្នុងគ្រប់ទាំងសាលាប្រជុំផង [២០]កាលដែលឈាម**
**ស្ទេផាន ជាស្មរបន្ទាល់របស់ទ្រង់ បានត្រូវខ្ចាយ នោះទូលបង្គំក៏**
**ឈរនៅទីនោះដែរ បានទាំងយល់ព្រមឲ្យសំឡាប់គាត់ ហើយនៅ**
**ចាំអាវនៃពួកអ្នក ដែលសំឡាប់គាត់ផង (កិច្ចការ២២:១៦-២០)។**

សាវ័កប៉ុលរំឭកដល់ពួកបណ្ដាជនថា លោកមិនភ្លេចនូវព្រឹត្តិការណ៍ ដែលលោកបានបង្គាប់គេអោយគប់លោកស្ទេផានសម្លាប់នឹងថ្ម។ លោកជាអ្នកទទួលខុសត្រូវក្នុងការធ្វើឃាតលោកស្ទេផាន។

**[២១]នោះទ្រង់មានបន្ទូលមកខ្ញុំថា ចូរទៅចុះ ដ្បិតខ្ញុំនឹងចាត់អ្នកឲ្យ**
**ទៅឯសាសន៍ដទៃដែលនៅឆ្ងាយ [២២]គេក៏ស្តាប់គាត់ដរាបដល់**
**ពាក្យនោះ រួចគេស្រែកកាត់ឡើងថា ចូរដកមនុស្សយ៉ាងនេះពី**

**ផែនដីចេញ ដ្បិតមិនគួរឱ្យវានៅរស់ទៀតទេ (កិច្ចការ២២:២១-២២)។**

សាវ័កប៉ុលចាប់ផ្តើមនិយាយពីសាសន៍ដទៃ ពីព្រោះលោកបានធ្វើដំណើរទៅផ្សាយដំណឹងប្រាប់សាសន៍ដទៃ អោយគេបានជឿដល់ព្រះអម្ចាស់យេស៊ូវ។ សាសន៍យូដាជ្រាបច្បាស់អំពីដំណើរនេះ។ នៅក្នុងវិនាទីដែលសាវ័កប៉ុលនិយាយអំពីរឿងសាសន៍ដទៃ ពួកយូដានាំគ្នាកម្រើកកំហឹងរបស់គេឆេះកញ្ច្រោលឡើង។ ដោយសារដំណើរនោះ គេមិនស្តាប់ដល់សាវ័កប៉ុលទៀតទេ។

**២៣ ហើយដោយព្រោះគេចេះតែស្រែកឡើង ទាំងកន្ត្រាក់ដោះអាវគេចេញ ហើយបាចធូលីដីទៅលើ ២៤ នោះបានជាមេទ័ពធំបង្គាប់ឱ្យនាំគាត់ចូលទៅក្នុងបន្ទាយ រួចប្រាប់ឱ្យវាយសួរចំឡើយ ដើម្បីឱ្យដឹងពីហេតុអ្វី បានជាគេស្រែកទាស់នឹងគាត់ជាខ្លាំងម្ល៉េះ (កិច្ចការ ២២:២៣-២៤)។**

សាវ័កប៉ុលនិយាយជាភាសាហេព្រើរទៅកាន់ពួកបណ្តាជន។ លោកមេទ័ពដែលចាប់លោក មិនយល់សេចក្តីដែលសាវ័កប៉ុលនិយាយទៅកាន់បណ្តាជន ពីព្រោះមេទ័ពរូបនេះមិនចេះភាសាហេព្រើរឡើយ។ ដោយសារលោកមិនយល់ថា សាវ័កប៉ុល

កំពុងនិយាយពីរឿងអ្វី លោកក៏ចាប់កន្ត្រាក់សាវ័កប៉ុលចូលទៅក្នុងបន្ទាយ។ មេទ័ពរូប នោះយល់ថា សាវ័កប៉ុលជាកម្ពុចកម្ម បានជាចង់ចាប់យកលោកចូលទៅក្នុងបន្ទាយ រកអោយដឹងខុសត្រូវ។ លោកធ្វើការនោះ ដោយវាយដំច្រំផាក់សាវ័កប៉ុល តាមតែ អំពើចិត្តរបស់លោក។

## សាវ័កប៉ុលប្រាប់គេថា លោកមានសញ្ជាតិជាសាសន៍រ៉ូម

**ប៉ុន្តែ កំពុងដែលគេយកខ្សែមកចងប៉ុលឲ្យចំកោង នោះគាត់ និយាយទៅមេទ័ពរងដែលឈរនៅទីនោះថា តើមានច្បាប់នឹង វាយសាសន៍រ៉ូមនឹងរំពាត់ មុនដែលកាត់ទោសដែរឬអី (កិច្ចការ ២២:២៥)។**

មនុស្សម្នាក់ៗសុទ្ធតែនាំគ្នាយល់ច្រឡំចំពោះសាវ័កប៉ុលទាំងអស់។ ពួកសាសន៍ យូដាយល់ថា លោកបាននាំលោកទ្រភីមជាសាសន៍ដទៃ ចូលទៅក្នុងព្រះវិហារ។ តាមពិតលោកមិនបានធ្វើការនោះទេ។ ចំណែកឯលោកមេទ័ពវិញ យល់ថា សាវ័កប៉ុល ជាសាសន៍អេស៊ីព្ទម្នាក់ដែលនាំគេបះបោរ។ តាមពិតទៅសាវ័កប៉ុលមិនមែនជាសាសន៍ អេស៊ីព្ទនោះទេ។ តើសាវ័កប៉ុលជានរណា? សាវ័កប៉ុលជាសាសន៍ហេព្រើរ តែចេះ

និយាយភាសាក្រេកយ៉ាងស្ទាត់ជំនាញ។ លោកមានសញ្ជាតិជាសាសន៍រ៉ូមទៀតផង។ នៅពេលដែលគេវាយធ្វើបាបលោក លោកប្រាប់ដល់អ្នកធ្វើបាបលោកថា លោកមានសញ្ជាតិជាសាសន៍រ៉ូម ដើម្បីកុំអោយគេវាយធ្វើទុក្ខបុកម្នេញដល់លោកខុសច្បាប់តុលាការ។ នៅសម័យនោះ ជនជាតិណាក៏ដោយ អោយតែខុសអំពីអ្នកដែលមានសញ្ជាតិរ៉ូម សុទ្ធតែកើតមកក្នុងពូជខ្ញុំគេទាំងអស់។ សាសន៍រ៉ូម គឺជាសាសន៍មួយ ដែលកើតមកសម្រាប់មានសេរីភាព។

> **[២៦] លុះមេទ័ពរងឮដូច្នោះ នោះក៏ទៅជំរាបដល់មេទ័ពធំថា លោក**
> **គិតធ្វើអ្វីដូច្នេះ ដ្បិតមនុស្សនោះជាសាសន៍រ៉ូម [២៧] នោះមេទ័ពធំ**
> **ចូលមកសួរប៉ុលថា ចូរប្រាប់អញ ឯងជាសាសន៍រ៉ូមឬ គាត់ឆ្លើយ**
> **ថា បាទ [២៨] លោកក៏និយាយថា អញបានបង់ប្រាក់ច្រើនណាស់**
> **ដើម្បីឱ្យបានចូលជាតិរ៉ូមនេះ តែប៉ុលនិយាយថា ខ្ញុំនេះកើតមកជា**
> **សាសន៍រ៉ូមតែម្តង (កិច្ចការ២២:២៦-២៨)។**

មេទ័ពរូបនេះ ធ្លាប់ធ្វើជាទាសករមួយរូបរបស់រាជការរ៉ូម។ គាត់បានសន្សំប្រាក់កាក់យ៉ាងក្រាស់ក្រែល ដើម្បីទិញសេរីភាពរបស់លោក។ នៅពេលលោកមានសេរីភាពហើយ លោកចូលបម្រើក្នុងកងទ័ពរ៉ូម រហូតដល់ទទួលបានឋានន្តរស័ក្តិជាមេទ័ព។ លោកមេទ័ពមានការអស្ចារ្យនៅក្នុងចិត្តដោយដឹងថា នៅក្នុងដៃរបស់លោក

មានអ្នកជាប់គុកម្នាក់ជាសាសន៍រ៉ូម។ ធម្មតាសាសន៍រ៉ូម កើតមកមានសេរីភាពពីពោះម្ដាយមក។

> **២៩ដូច្នេះ ពួកអ្នកដែលត្រូវសួរចំឡើយ ក៏ថយចេញជា១រំពេច ហើយមេទ័ពធំមានសេចក្ដីភិតភ័យ ដោយដឹងថា គាត់ជាសាសន៍រ៉ូម ពីព្រោះបានជ្រុលជាចងគាត់ហើយ ៣០ដល់ថ្ងៃស្អែកឡើង លោកក៏ស្រាយចំណង ហើយប្រាប់ដល់ពួកសង្គ្រាជ នឹងពួកក្រុមជំនុំទាំងអស់ ឲ្យប្រជុំគ្នា រួចលោកនាំប៉ុលចុះមក ដាក់នៅកណ្ដាលពួកគេដោយចង់ដឹងច្បាស់ ពីហេតុអ្វីបានជាពួកសាសន៍យូដាចោទប្រកាន់គាត់ដូច្នោះ (កិច្ចការ២២:២៩-៣០)។**

ពេលនេះទើបលោកមេទ័ពជ្រាបថា សាវ័កប៉ុលមិនមែនជាមនុស្សសាមញ្ញធម្មតាទេ។ លោកជាអ្នកចេះដឹង ដ្បិតលោកចេះនិយាយភាសាក្រេកយ៉ាងស្ទាត់ជំនាញ។ លោកជាសាសន៍យូដា តែមានសញ្ជាតិជាសាសន៍រ៉ូម។ ដូច្នេះហើយ បានជាលោកមេទ័ពមិនហ៊ានធ្វើបាបសាវ័កប៉ុលក្រៅច្បាប់តុលាការឡើយ។ លោកមេទ័ពរៀបចំដើម្បីអោយសម្ដេចសង្ឃ និងក្រុមតុលាការបានស្ដាប់រឿងក្ដីរបស់សាវ័កប៉ុល។

សាវ័កប៉ុល មានទុនជាច្រើនសម្រាប់ខ្លួនលោក។ ដូច្នេះហើយ បានជាលោកសមនឹងធ្វើជាបេសកជនដើរផ្សព្វផ្សាយដំណឹងល្អនៅក្នុងចក្រភពរ៉ូមទាំងមូល។ លោក

មានទស្សនៈយល់ដឹងស្តីពីពិភពលោកយ៉ាងទូលំទូលាយ។ លោកជាមនុស្សដែលចេះភាសាក្រេក បានជាលោកអាចសរសេររឿងរ៉ាវផ្សេងៗបាន អំពីដំណើរគ្រីស្ទបរិស័ទនៅក្នុងសតវត្សរ៍ទីមួយ។ លោកទទួលការបង្ហឹកបង្វឹនចេះច្បាប់និងក្រឹត្យវិន័យរបស់លោកម៉ូសេ។ ដោយហេតុនោះហើយ បានជាលោកអាចបកស្រាយព្រះគម្ពីរបានយ៉ាងត្រឹមត្រូវ ស្តីអំពីគោលទិទ្ធិនៃការដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទយាងមក ព្រមទាំងការសង្គ្រោះដល់មនុស្សមានបាបតាមរយៈសេចក្តីសុគត និងការរស់ឡើងវិញនៃព្រះអម្ចាស់យេស៊ូវ។ មិនតែប៉ុណ្ណោះ ទុនដ៏ធំដែលលោកមាននៅក្នុងសម័យនោះ គឺមានសញ្ជាតិជាសាសន៍រ៉ូម។ ដូច្នេះហើយ បានជាលោកចង់ធ្វើដំណើរទៅទីណាតាមតែចិត្តលោកចង់អោយតែស្ថិតនៅក្នុងទឹកដីដែលចក្រភពរ៉ូមគ្រប់គ្រង។ សូមកុំភ្លេចថា សម័យនោះពិភពលោកទាំងមូលស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់ចក្រភពរ៉ូម។

យើងស្លេះការសិក្សាគម្ពីរកិច្ចការត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"